មូលនិធិខ្មែរសម្រាប់ការសិក្សា
Cambodian Education Excellence Foundation
ផ្តល់លទ្ធភាពសិក្សាស្មើភាពគ្នា    Equal Education Opportunity for All.
12739 Knightsbridge Drive, Woodbridge, VA 22192. Tel: (703) 670-0854. ceefusa@ceefoundation.org www.ceefoundation.org

# សុន្ទរកថា (តាមវីដេអូ) របស់ លោក ចៅ ចេន

អនុប្រធានអង្គការភិបាល នៃមូលនិធិខ្មែរសម្រាប់ការសិក្សា
ក្នុងពិធីផ្តល់អាហារូបករណ៍ដល់និស្សិតក្រីក្រ និងរៀនពូកែ – វិជ្ជាស្ថានបច្ចេកវិទ្យាកម្ពុជា នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧

*ជាបឋម ខ្ញុំសូមថ្លែងអំណរគុណដល់សមាជិកសមាជិកាស្ម័គ្រចិត្តធ្វើការរបស់មូលនិធិនៅស្រុកខ្មែរទាំងអស់ ដែលបាន ខិតខំបំពេញកិច្ចការរបស់មូលនិធិ ចាប់តាំងពីការទៅរកកូនសិស្ស សម្ភាសកូនសិស្ស ជ្រើសរើសយកកូនសិស្សអោយ គណកម្មការ ជ្រើសរើសនៅស្រុកអាមេរិកហើយនៅថ្ងៃនេះទៀត បានរៀបចំពិធីផ្តល់អាហារូករណ៍ ដ៏មហោឡារិកនេះ។ ខ្ញុំសូមគោរពនិងកោតសរសើរដល់ពលិកម្មដ៏ខ្ពង់ខ្ពស់របស់សហការីទាំងអស់ដោយស្មោះអស់ពីដួងចិត្ត ។*

*ជាបន្ទាប់មកទៀត ខ្ញុំសូមស្វាគមន៍និងថ្លែងសេចក្តីសរសើរដល់និស្សិតទទួលអាហារូបករណ៍ទាំងអស់ ដែលមកចូលរួម ក្នុងពិធីទទួលយកអាហារូបករណ៍នេះ។ ខ្ញុំពុំមានពាក្យអ្វីនិយាយច្រើនទេ គ្រាន់តែមានពាក្យបណ្តាំខ្លះៗ ដើម្បីជាការរំលឹក ដល់ស្មារតីដល់ក្មួយប្រុសក្មួយស្រីទាំងអស់គ្នា ។ មូលនិធិយើងមានគោលបំណង សំខាន់បីយ៉ាងដែលយើងចង់អោយ និស្សិតទាំងអស់ជួយបំពេញ ។*

*ទីមួយ យើងចង់អោយនិស្សិតយើងម្នាក់ៗខិតខំរៀនសូត្រអោយបានសម្រេចគោលបំណងរបស់ខ្លួន ហើយនៅពេលរៀន ចប់ហើយ យកចំណេះវិជ្ជាទាំងនោះមកធ្វើការចិញ្ចឹមជីវិតខ្លួនឯងនិងជួយឧបត្ថម្ភឪពុកម្តាយនិងក្រុមគ្រួសារអោយបាន ចំរើនរុង រឿងទៅមុខ ។*

*ទីពីរ ដល់ពេលខ្លួនឯងមានជីវភាពធូរធាហើយ សូមជួយកសាងសង្គមនិងប្រទេសជាតិយើង ដើម្បីអោយប្រទេសជាតិ យើងមានភាពចំរើនលូតលាស់ មានអ្នកចេះ ដឹងច្រើន អាចមានលទ្ធភាពប្រកួតប្រជែងជាមួយប្រទេសជិតខាង និង លើឆាកអន្តរជាតិផង។*

*ទីបី យើងចង់អោយនិស្សិតយើងម្នាក់ៗមានចិត្តគំនិតល្អ មានសីលធម៌ ប្រកាន់សុច្ចរិត យុត្តិធម៌ ធ្វើជាគំរូនិងជួយបណ្តុះ បណ្តាលដល់កូនក្មេងជំនាន់ក្រោយផង ។ ដល់ពេលខ្លួនឯងមានជីវភាពធូរធាហើយ ចូរកុំភ្លេចជួយអ្នកក្រីក្រដាង់ខ្លួនផង ដែរ ។*

*សុប្បុរសជនជាម្ចាស់ប្រាក់អំណោយអាហារូបករណ៍ទាំងអស់ ក៏គាំទ្រនូវគោលគំនិតទាំងបីយ៉ាងនេះដែរ។ ចូរក្មួយប្រុស ក្មួយស្រីជួយមូលនិធិយើងអោយបានសម្រេចនូវគោលបំណងនេះ ជាស្ថាពរ ។*
*អរគុណ។*